**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៤៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបំពេញបន្ថែម ឯកសណ្ឋាន របស់នាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល"
- តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១ :**

បំពេញបន្ថែម ខ្លឹមសារមួយចំនួនលើអនុក្រឹត្យលេខៈ ១៨៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់ របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និង បង្រ្កាបការក្លែងបន្លំ "កាំកុងត្រូល" សំរាប់មន្ត្រីរាជការ ប្រើប្រាស់ក្នុងពេលប្រតិបត្តិការ នៅមន្ទីរពិសោធន៍, នៅទីផ្សារ, នៅតាមព្រំដែន និងប្រើប្រាស់សំរាប់ពិធីការ ។

**មាត្រា ២ :**

ខ្លឹមសារដែលត្រូវបំពេញបន្ថែម ត្រូវបានកំណត់ដូចតទៅ ÷

១- ឯកសណ្ឋាន :

- អាវសំរាប់ប្រើប្រាស់នៅ មន្ទីរពិសោធន៍

ប្រភេទអាវដៃវែង សំរុងត្រឹមក្បាលជង្គង់ សំរាប់ពាក់ខាងក្រៅ ផលិតអំពីសាច់ក្រណាត់ដែលមានធាតុផ្សំ ហុកសិបប្រាំភាគរយ ប៉ូលីយ៉ៃស្ទើរ និងសាមសិបប្រាំភាគរយ កូតុង មានពណ៌ស កបើក ថ្នេរខុប ឡេវខាងមុខ មានហោប៉ៅបី " ហោប៉ៅមួយ នៅឆ្វេងដៃខាងលើ លើហោប៉ៅមានឌិន សញ្ញារបស់ នាយកដ្ឋានកាំកុងត្រូល ខាងក្រោមរូបសញ្ញានេះមានឌិនអក្សរឡាតាំង CTL បញ្ជាក់ពីឈ្មោះមន្ទីរពិសោធន៍ (CAMCONTROL Testing Laboratory) ហោប៉ៅពីរទៀតនៅខាងក្រោម ត្រឹមចង្កេះ " ផ្នែកខាង ក្រោយអាវ មាននែកចំកណ្តាល ។

- អាវសំរាប់បំពេញប្រតិបត្តិការ នៅតាមព្រំដែន

ប្រភេទអាវដៃវែងពាក់ខាងក្រៅ ផលិតអំពីសាច់ក្រណាត់មួយរយភាគរយកូតុង មានពណ៌ខៀវប្រផេះ កបើក ថ្នេរខុប មានឡេវរ៉ូតពីក្រោមរហូត ដល់លើ ផ្នែកខាងក្រោមមានក្រវ៉ាត់ចង្កេះសងខាង និង មានហោប៉ៅបួន (ហោប៉ៅពីរនៅខាងក្រោម ដេរបង្កប់តាមថ្នេរ ឆ្វេងមួយ ស្តាំមួយ និងហោប៉ៅពីរទៀត នៅខាងក្នុងអាវ ផ្នែកមុខ ឆ្វេងមួយ ស្តាំមួយ) ។ ផ្នែកមុខស្តាំដៃ ខាងលើ មានឌិនអក្សរថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកខាងក្រោយអាវ មានឌិនអក្សរឡាតាំងរាងកោងបន្តិចចំកណ្តាល ថា " CAMCONTROL " ពណ៌ពងក្រសារ ។

- អាវសំរាប់ពិធីការ មាន ពីរ ថ្នាក់ :

  - ថ្នាក់ដឹកនាំនាយកដ្ឋាន ថ្នាក់ប្រធានការិយាល័យ និងប្រធានសាខា

ប្រភេទអាវធំដៃវែង ផលិតអំពីសាច់ក្រណាត់តេហ្គាឡែន ពណ៌ពងក្រសារចាស់ កបើក ថ្នេរខុប ប៉ូលស្មា ជីបក្លីខាងមុខពីរ មានឡេវធំពីក្រោមរហូតដល់លើពណ៌ទឹកមាស ហោប៉ៅបួន (ហោប៉ៅពីរ ខាងលើ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ ដោយមានឡេវធំពណ៌មាស

ហោប៉ៅពីរទៀត នៅក្រោម មានគំរបរាងចតុកោណកែង ដោយមាន ឡេវធំពណ៌មាស ។ ផ្នែកខាងក្រោយមាន ជីបក្លីចំនួនពីរ ឆ្វេងមួយ ស្តាំមួយ និងមានផែកចំកណ្តាលនៃអាវ ។

- ថ្នាក់អនុប្រធានការិយាល័យ-អនុសាខា និងមន្ត្រីភ្នាក់ងារ

ប្រភេទអាវធំដៃវែង ផលិតអំពីសាច់ក្រណាត់តេហ្គាឡែន ពណ៌ពងក្រសារចាស់ ករបើក ផ្ទេរខុប ប៉ូលស្មា ជីបក្លីខាងមុខពីរ មានឡេវធំពីក្រោមរហូតដល់លើពណ៌ទឹកប្រាក់ ហោប៉ៅបួន (ហោប៉ៅពីរ ខាងលើ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ ដោយមានឡេវធំពណ៌ប្រាក់ ហោប៉ៅពីរទៀត នៅក្រោម មានគំរបរាងចតុកោណកែង ដោយមាន ឡេវធំពណ៌ប្រាក់ ។ ផ្នែកខាងក្រោយមាន ជីបក្លីចំនួនពីរ ឆ្វេងមួយ ស្តាំមួយ និងមានផែកចំកណ្តាលនៃអាវ ។

អាវសំរាប់ពិធីការនេះ ពាក់ពីខាងក្រៅ ចំពោះអាវខាងក្នុងគឺជាអាវសឺមី ពណ៌ស ដៃវែងភ្ជាប់ក្រវ៉ាត់ក ពណ៌ខៀវទឹកប៊ិច ។

២- មួក :

- មួក សំរាប់បំពេញប្រតិបត្តិការនៅព្រំដែន និងនៅទីផ្សារ មាន ៣ ថ្នាក់ :
  - ថ្នាក់ដឹកនាំ នាយកដ្ឋាន

មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខ មានភ្ជាប់រូបព្រះសង្ហា ពណ៌មាស មានក្បាច់ភ្ញីទេស ឌិនពណ៌មាស ទំរង់ស្លែងក្របីទ្រព្រះសង្ហា និងមានក្បាំងពណ៌ដូចតួមួក ។ ផ្នែកចំហៀង ខាងឆ្វេង មានឌិនអក្សរ ថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកចំហៀងខាងស្តាំ មានឌិនអក្សរឡាតាំង ថា " CAMCONTROL " ពណ៌ពងក្រសារ ។

  - ថ្នាក់ការិយាល័យ និងសាខា ( បុរស )

មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខ មានភ្ជាប់រូបព្រះសង្ហា ពណ៌មាស និងមានក្បាំងពណ៌ដូចតួមួក ។ ផ្នែកចំហៀងខាងឆ្វេង មានឌិនអក្សរ ថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកចំហៀងខាងស្តាំ មានឌិនអក្សរឡាតាំង ថា "CAMCONTROL" ពណ៌ពងក្រសារ ។

  - ថ្នាក់ការិយាល័យ និងសាខា ( ស្ត្រី )

មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខ មានភ្ជាប់រូបព្រះសង្ហាពណ៌មាស មានក្បាំងខាងមុខ និងបទឡើងលើពីចំហៀងព័ទ្ធសងខាងមួក រហូតដល់ក្រោយ ប្រៀបដូចកណ្តាប់វ័ន្ត ពណ៌ដូចតួមួក ។ ផ្នែកចំហៀង ខាងឆ្វេងមានឌិនអក្សរ ថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកចំហៀង ខាងស្តាំ មានឌិនអក្សរឡាតាំង ថា "CAMCONTROL" ពណ៌ពងក្រសារ ។

- ថ្នាក់មន្ត្រីភ្នាក់ងារ ( បុរស )

មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ហា ពណ៌ប្រាក់ និងមានក្បាំងពណ៌ដូចតួមួក ។ ផ្នែកចំហៀង ខាងឆ្វេងមានឌិនអក្សរ ថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកចំហៀងខាងស្តាំ មានឌិនអក្សរឡាតាំងថា " CAMCONTROL " ពណ៌ពងក្រសារ ។

- ថ្នាក់មន្ត្រីភ្នាក់ងារ ( ស្ត្រី )

មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ហាពណ៌ប្រាក់ មានក្បាំងខាងមុខ និងបទឡើងលើពីចំហៀងព័ទ្ធសងខាងមួករហូតដល់ក្រោយ ប្រៀបដូចកណ្តាប់វ័ន្ត ពណ៌ដូចតួមួក ។ ផ្នែកចំហៀង ខាងឆ្វេងមានឌិនអក្សរថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកចំហៀង ខាងស្តាំ មានឌិនអក្សរឡាតាំងថា " CAMCONTROL " ពណ៌ពងក្រសារ ។

**មាត្រា ៣ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ